## មណ្ឌលសេវាពេទ្យសហគមន៍

## ព័ត៌មានសំខាន់អំពីការទូទាត់វិក្កយបត្រសម្រាប់អ្នកជំងឺ

មណ្ឌលសេវាពេទ្យសហគមន៍ (CMC) មានប្រវត្តិដ៏យូរលុងនៃការផ្តល់ការតបស្នងដល់សហគមន៍។ ការប្តេជ្ញាចិត្តរបស់យើងត្រូវបានឆ្លុះបញ្ចាំងតាមរយៈគោលនយោបាយស្តីពីជំនួយហិរញ្ញវត្ថុសប្បុរសធម៌របស់យើងសម្រាប់អ្នកជំងឺដែលស្វែងរកសេវាថែទាំនៅតាមបណ្តាមន្ទីរពេទ្យរបស់យើង។ ឯកសារនេះមានព័ត៌មានសំខាន់ដើម្បីជួយអ្នកជំងឺរបស់យើងស្វែងយល់ពីនីតិវិធីទូទាត់វិក្កយបត្ររបស់យើង ជម្រើសនៃការទូទាត់ប្រាក់ និងកម្មវិធីជំនួយហិរញ្ញវត្ថុ។ ច្បាប់សហព័ន្ធនិងច្បាប់រដ្ឋតម្រូវឱ្យមន្ទីរពេទ្យផ្តល់សេវាព្យាបាលជំងឺដោយឥតគិតថ្លៃ ឬបញ្ចុះតម្លៃជូនដល់អ្នកជំងឺគ្មានការធានារ៉ាប់រង និងអ្នកជំងឺមានការធានារ៉ាប់រងមិនគ្រប់គ្រាន់ ដែលមានការចំណាយថ្លៃពេទ្យខ្ពស់។ បុគ្គលដែលដាក់ពាក្យសុំ និងមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុ អាចមិនគិតថ្លៃលើសេវាសង្គ្រោះបន្ទាន់ ឬសេវាថែទាំចាំបាច់ផ្នែកវេជ្ជសាស្ត្រផ្សេងទៀតក្នុងតម្លៃថ្លៃជាងបុគ្គលដែលមានការធានារ៉ាប់រងលើសេវាថែទាំបែបនេះ។ ព័ត៌មាននេះអនុវត្តតែចំពោះវិក្កយបត្ររបស់មន្ទីរពេទ្យនេះ ហើយមិនអនុវត្តចំពោះវិក្កយបត្រដែលអ្នកទទួលបានពីគ្រូពេទ្យ គ្រូពេទ្យជំនាញថ្នាំស្ពឹក អ្នកជំនាញផ្នែកគ្លីនិក ក្រុមហ៊ុនផ្តល់សេវារថយន្តសង្គ្រោះបន្ទាន់ ឬគ្រូពេទ្យជំនាញផ្សេងទៀតដែលអាចត្រូវបានផ្តល់ជូនការព្យាបាលវេជ្ជសាស្ត្រនៅមណ្ឌលសេវាពេទ្យសហគមន៍ (CMC)។

**ជំនួយហិរញ្ញវត្ថុ(សេវាថែទាំមនុស្សធម៌)៖**អ្នកជំងឺគ្មានការធានារ៉ាប់រងមានប្រាក់ចំណូលទាប និងអ្នកជំងឺមានការធានារ៉ាប់រងមិនគ្រប់គ្រាន់មានប្រាក់ចំណូលទាបដែលមានការចំណាយថ្លៃពេទ្យខ្ពស់អាចមានសិទ្ធិទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ។ សិទ្ធិទទួលបានសេវានេះគឺផ្អែកលើប្រាក់ចំណូល និងទំហំគ្រួសារ។ ប្រភពអ្នកចេញប្រាក់ទាំងអស់ត្រូវតែប្រើប្រាស់ឲ្យអស់មុនពេលដែលអ្នកជំងឺណាមានសិទ្ធិទទួលសេវាថែទាំដោយឥតគិតថ្លៃ។

**សេវាថែទាំបញ្ចុះតម្លៃ៖** ប្រសិនបើអ្នកជំងឺមិនមានសិទ្ធិទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ អ្នកជំងឺនេះអាចនៅតែមានសិទ្ធិទទួលបានសេវាថែទាំបញ្ចុះតម្លៃ។ សិទ្ធិទទួលបានសេវានេះគឺផ្អែកលើប្រាក់ចំណូលគ្រួសារនិងទំហំគ្រួសារ។ គ្រូពេទ្យដែលផ្តល់សេវាសង្គ្រោះបន្ទាន់នៅមណ្ឌល CMC តម្រូវឲ្យផ្តល់ការបញ្ចុះតម្លៃជូនដល់អ្នកជំងឺគ្មានការធានារ៉ាប់រង ឬអ្នកជំងឺមានការធានារ៉ាប់រងមិនគ្រប់គ្រាន់ ដែលមានការចំណាយថ្លៃពេទ្យខ្ពស់ ដែលជាអ្នកនៅ ឬក្រោម 350% នៃកម្រិតភាពក្រីក្ររបស់សហព័ន្ធ។ អ្នកនឹងទទួលបានវិក័យប័ត្រដាច់ដោយឡែកមួយសម្រាប់សេវាសង្គ្រោះបន្ទាន់ដែលអ្នកទទួលបាននៅមណ្ឌល CMC ។ សំណួរណាមួយដែលអ្នកមានអំពីវិក្កយបត្ររបស់គ្រូពេទ្យគួរតែត្រូវបានបញ្ជូនទៅការិយាល័យរបស់គ្រូពេទ្យ។

**គោលនយោបាយជំនួយហិរញ្ញវត្ថុ និងការដាក់ពាក្យ៖** ច្បាប់ចម្លងនៃគោលនយោបាយរបស់ CMC ស្តីពីជំនួយហិរញ្ញវត្ថុ និងពាក្យស្នើសុំសេវាពេទ្យដោយឥតគិតថ្លៃ ឬ ដោយបញ្ចុះតម្លៃអាចរកឃើញនៅគេហទំព័រ៖ www.communitymedical.org ។ ច្បាប់ចម្លងនៃគោលនយោបាយស្តីពីជំនួយហិរញ្ញវត្ថុ និងពាក្យស្នើសុំជំនួយហិរញ្ញវត្ថុរបស់ CMC គឺអាចរកបាននៅផ្នែកអនុញ្ញាតឲ្យចូលដេកពេទ្យរបស់យើងតាមទីតាំងដូចខាងក្រោម៖ មណ្ឌលសេវាពេទ្យតំបន់សហគមន៍៖ វិថី 2823 Fresno, Fresno, CA 93721។ មណ្ឌលសេវាពេទ្យសហគមន៍ Clovis ៖ - វុក្ខវិថិ 2755 Herndon, Clovis, CA 93611 និងមណ្ឌលសេវារះកាត់និងបេះដូង Fresno ៖-15 E. Audubon Drive, Fresno, CA 93720។ ដើម្បីទទួលបានដោយឥតគិតថ្លៃនូវច្បាប់ចម្លងនៃគោលនយោបាយ និងពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ តាមរយៈការផ្ញើសំបុត្រ  សូមស្នើសុំច្បាប់មួយដោយហៅទៅកាន់ផ្នែកអនុញ្ញាតឲ្យចូលដេកពេទ្យតាមលេខ៖ (559) 459-2998។ សំណៅបកប្រែនៃគោលនយោបាយ និងពាក្យស្នើសុំជំនួយហិរញ្ញវត្ថុមានជាភាសាអេស្ប៉ាញ ម៉ុង ប៉ាន់ចាប៊ី ឡាវ តាហ្គាឡុក ខ្មែរ/កម្ពុជា អាមេនី អារ៉ាប់ ចិន វៀតណាម អាល្លឺម៉ង់ កូរ៉េ ជប៉ុន រុស្ស៊ី ហិណ្ឌូ ព័រទុយហ្គាល់      ពែក និងភាសាចិនកុកងឺ។

**ជំនួយក្នុងការដាក់ពាក្យ៖** ផ្នែកអនុញ្ញាតឲ្យចូលដេកពេទ្យរបស់ CMC (ដូចដែលបានរាយខាងលើ) នៅប្រចាំការចាំជួយអ្នកក្នុងការដំណើរការដាក់ពាក្យ។ អ្នកនឹងត្រូវបានស្នើឲ្យបំពេញពាក្យស្នើសុំ និងផ្តល់ឯកសារបញ្ជាក់ពីប្រាក់ចំណូលគ្រួសាររបស់អ្នក។ អ្នកជំងឺគួរតែផ្ញើពាក្យស្នើសុំជំនួយហិរញ្ញវត្ថុទៅកាន់៖ មណ្ឌលសេវាពេទ្យសហគមន៍ ផ្នែកសេវាហិរញ្ញវត្ថុអ្នកជំងឺ តាមប្រអប់សំបុត្រ៖ 1232, Fresno, CA 93715 តាមរយៈពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ។ បន្ទាប់ពីផ្ញើពាក្យស្នើសុំ និងឯកសាររបស់អ្នក គេនឹងទាក់ទងអ្នកសួរអំពីសិទ្ធិរបស់អ្នកក្នុងទទួលបានជំនួយហិរញ្ញវត្ថុ។ ប្រសិនបើអ្នកគិតថា អ្នកអាចមានសិទ្ធិទទួលសេវាថែទាំសុខភាពដោយឥតគិតថ្លៃ ឬដោយបញ្ចុះតម្លៃ សូមទាក់ទង៖ ផ្នែកអនុញ្ញាតឲ្យចូលដេកពេទ្យតាមលេខ៖ (559) 459-2998 ចំពោះព័ត៌មានបន្ថែម។

**សេវាដែលទទួលបាន៖** អ្នកជំងឺដែលមានសិទ្ធិអាចទទួលបានសេវាថែទាំដោយបញ្ចុះតម្លៃ ឬដោយឥតគិតថ្លៃសម្រាប់សេវាសង្គ្រោះបន្ទាន់ និងសេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រនៅមណ្ឌលសេវាពេទ្យសហគមន៍(CMC)។ ទំនិញ និងសេវាកម្មដែល (1)  មិនចាំបាច់ផ្នែកវេជ្ជសាស្ត្រក្នុងការព្យាបាលរបួស ឬជំងឺ (2) ផ្តល់ជូនជាចម្បងសម្រាប់គោលបំណងកែសម្ផស្ស ឬ (3)  ទំនិញពិសោធន៍ឬសេវាកម្មពិសោធន៍ ដែលរួមបញ្ចូលទាំងសេវាកម្មដែលបានផ្តល់ជូនអ្នកជំងឺជាផ្នែកមួយនៃកម្មវិធីសាកល្បង និងស្រាវជ្រាវផ្នែកគ្លីនិកជាដើមគឺមិនមានសិទ្ធិទទួលការបញ្ចុះតម្លៃ ឬជំនួយសប្បុរសធម៌។

**សិទ្ធិទទួលបានកម្មវិធីរបស់រដ្ឋាភិបាល៖** អ្នកអាចមានសិទ្ធិទទួលបានកម្មវិធីអត្ថប្រយោជន៍ផ្នែកសុខភាពដែលឧបត្ថម្ភដោយរដ្ឋាភិបាល។ CMC មានបុគ្គលិកចាំជួយលោកអ្នកក្នុងការដាក់ពាក្យសុំជំនួយពីរដ្ឋាភិបាលដើម្បីបង់វិក្កយបត្រថ្លៃពេទ្យរបស់អ្នក ។ អ្នកអាចទទួលបានជំនួយតាមរយៈការដាក់ពាក្យសុំអត្ថប្រយោជន៍ផ្នែកសុខភាពដែលឧបត្ថម្ភដោយរដ្ឋាភិបាលដោយទាក់ទងផ្នែកអនុញ្ញាតឲ្យចូលដេកពេទ្យតាមលេខ៖ (559) 459-2998។

**ពាក្យដែលកំពុងរង់ចាំការឆ្លើយតប៖** បើអ្នកជំងឺដាក់ពាក្យ ឬបានដាក់ពាក្យហើយរង់ចាំឆ្លើយតបចំពោះកម្មវិធីធានារ៉ាប់រងសុខភាពមួយផ្សេងទៀតនៅពេលដែលពួកគេដាក់ពាក្យសុំសេវាថែទាំមនុស្សធម៌ ឬបញ្ចុះតម្លៃនៅមណ្ឌល CMC  គ្មានពាក្យណាមួយនឹងច្រានចោលសិទ្ធិទទួលបានកម្មវិធីផ្សេងទៀតទេ។

**ជម្រើសនៃការទូទាត់៖** CMC មានជម្រើសជាច្រើននៃការទូទាត់ប្រាក់ដើម្បីជួយលោកអ្នកក្នុងការទូទាត់វិក្កយបត្រថ្លៃពេទ្យរបស់អ្នក។ សមតុល្យគណនីរបស់អ្នកជំងឺត្រូវទូទាត់នៅពេលទទួលបានវិក្កយបត្រ ប៉ុន្តែគម្រោងពន្យាពេលទូទាត់ប្រាក់ក៏អាចផ្តល់ជូនសម្រាប់អ្នកជំងឺដែលស្នើសុំជំនួយហិរញ្ញវត្ថុ។ បើ CMC និងអ្នកជំងឺដែលមានសិទ្ធិមិនអាចឯកភាពចំពោះចំនួនទឹកប្រាក់ទូទាត់ប្រចាំខែសមរម្យ មន្ទីរពេទ្យនឹងប្រើរូបមន្តដែលបានរៀបរាប់នៅមាត្រារង (i) នៃមាត្រាទី 127400 នៃច្បាប់ស្តីពីសុខភាព និងសុវត្ថិភាពនៃរដ្ឋកាលីហ្វ័រញ៉ាដើម្បីបង្កើតគម្រោងទូទាត់ដ៏សមរម្យ។

**សេចក្តីជូនដំណឹងអំពីលទ្ធភាពនៃការប៉ាន់ប្រមាណហិរញ្ញវត្ថុ៖** អ្នកអាចស្នើសុំរបាយការណ៍ប៉ាន់ប្រមាណជាលាយលក្ខណ៍អក្សរអំពីការទទួលខុសផ្នែកហិរញ្ញវត្ថុរបស់អ្នកសម្រាប់សេវាមន្ទីរពេទ្យ។ សំណើសុំរបាយការណ៍ប៉ាន់ប្រមាណនេះត្រូវតែត្រូវបានធ្វើឡើងក្នុងអំឡុងពេលម៉ោងធ្វើការ។ របាយការណ៍ប៉ាន់ប្រមាណនេះនឹងផ្តល់ឱ្យអ្នកនូវការប៉ាន់ប្រមាណពីចំនួនទឹកប្រាក់ដែលមន្ទីរពេទ្យនឹងតម្រូវឱ្យអ្នកបង់ប្រាក់សម្រាប់សេវាថែទាំសុខភាព ការវះកាត់ និងគ្រឿងផ្គត់ផ្គង់ដែលត្រូវបានរំពឹងថាមានតម្លៃសមរម្យដែលត្រូវបានផ្តល់ដោយមន្ទីរពេទ្យនេះ។ ការប៉ាន់ស្មានត្រូវផ្អែកលើរយៈពេលនៃការដេកពេទ្យ និងសេវាកម្មដែលបានផ្តល់សម្រាប់ការធ្វើរោគវិនិច្ឆ័យរបស់អ្នកជំងឺ។ របាយការណ៍ទាំងនេះមិនមែនជាការសន្យាផ្តល់សេវាកម្មក្នុងតម្លៃថេរទេ។ ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់អ្នកជំងឺអាចច្រើនឬតិចជាងការប៉ាន់ប្រមាណដោយផ្អែកលើសេវាកម្មដែលអ្នកជំងឺទទួលបានជាក់ស្តែង។

មន្ទីរពេទ្យនេះអាចផ្តល់នូវការប៉ាន់ប្រមាណចំនួនទឹកប្រាក់សម្រាប់ថ្លៃសេវាមន្ទីរពេទ្យតែប៉ុណ្ណោះ។ អាចមានថ្លៃសេវាបន្ថែមសម្រាប់សេវាកម្មផ្សេងៗដែលគ្រូពេទ្យនឹងផ្តល់ជូនក្នុងអំឡុងពេលការស្នាក់នៅរបស់អ្នកជំងឺនៅក្នុងមន្ទីរពេទ្យដូចជាវិក្កយបត្រពីគ្រូពេទ្យផ្ទាល់ខ្លួន និងគ្រូពេទ្យជំនាញថ្នាំស្ពឹក  គ្រូពេទ្យជំនាញរោគសាស្ត្រ  គ្រូពេទ្យជំនាញផ្នែកវិទ្យុសាស្ត្រ ក្រុមហ៊ុនផ្តល់សេវារថយន្តសង្គ្រោះបន្ទាន់ ឬគ្រូពេទ្យជំនាញផ្សេងទៀត ដែលមិនមែនជាបុគ្គលិកនៃមន្ទីរពេទ្យនេះ។ អ្នកជំងឺនឹងទទួលបានវិក្កយបត្រដាច់ដោយឡែកមួយសម្រាប់សេវាកម្មទាំងនេះ។

ប្រសិនបើអ្នកមានសំណួរណាមួយអំពីរបាយការណ៍ប៉ាន់ប្រមាណថ្លៃពេទ្យជាលាយលក្ខណ៍អក្សរ សូមទាក់ទងផ្នែកសេវាហិរញ្ញវត្ថុអ្នកជំងឺតាមរយៈលេខ៖ (559) 459-3939 ។